ថ្ងៃទី១៥ ខែមិថុនា ឆ្នាំ២០០៩

# សេចក្តីប្រកាសព័ត៌មាន

## អង្គជំនុំជម្រះសាលាដំបូងសម្រេចបដិសេធសំណើសុំអោយដោះលែងជនជាប់ចោទ កាំង ហ្គេកអ៊ាវ ហៅឌុច នៅក្រៅឃុំដោយមានលក្ខខណ្ឌ

នៅក្នុងសេចក្តីសម្រេចចេញថ្ងៃទី១៥ ខែមិថុនា ឆ្នាំ២០០៩ អង្គជំនុំជម្រះសាលាដំបូងបានបដិសេធសំណើសុំដោះលែង កាំង ហ្គេកអ៊ាវ ហៅឌុច ពីការឃុំខ្លួនបណ្តោះអាសន្ន។ កាំង ហ្គេកអ៊ាវ បច្ចុប្បន្នកំពុងត្រូវបានជំនុំជម្រះក្តីពីបទឧក្រិដ្ឋកម្មប្រឆាំងនឹងមនុស្សជាតិ ឧក្រិដ្ឋកម្មសង្គ្រាម និងការរំលោភបំពានលើមាត្រាមួយចំនួននៃក្រមព្រហ្មទណ្ឌកម្ពុជាឆ្នាំ១៩៥៦។ សវនាការលើអង្គសេចក្តីបានចាប់ផ្តើមកាលពីថ្ងៃទី៣០ ខែមីនា ឆ្នាំ២០០៩ ហើយមេធាវីការពារក្តីអោយជនជាប់ចោទបានធ្វើសំណើដោយផ្ទាល់មាត់កាលពីថ្ងៃទី១ ខែមេសា ឆ្នាំ២០០៩ ស្នើសុំអោយដោះលែងជនជាប់ចោទនៅក្រៅឃុំសម្រាប់រយៈពេលសវនាការដោយមានលក្ខខណ្ឌ។

កាំង ហ្គេកអ៊ាវ ត្រូវបានដាក់ឲ្យស្ថិតក្នុងការឃុំខ្លួនបណ្តោះអាសន្នដោយអង្គជំនុំជម្រះវិសាមញ្ញក្នុងតុលាការកម្ពុជា (អ.វ.ត.ក) តាំងពីថ្ងៃ៣១ ខែកក្កដា ឆ្នាំ២០០៧។ មុនពេលត្រូវបានផ្ទេរមកកាន់មន្ទីរឃុំឃាំងរបស់អ.វ.ត.ក ជនជាប់ចោទត្រូវបានឃុំខ្លួនដោយតុលាការយោធាកម្ពុជាតាំងពីថ្ងៃទី១០ ខែឧសភា ឆ្នាំ១៩៩៩។

នៅក្នុងសេចក្តីសម្រេចរបស់ខ្លួន អង្គជំនុំជម្រះសាលាដំបូងបានយល់ឃើញថាការឃុំខ្លួនជនជាប់ចោទដោយតុលាការយោធាគឺមិនត្រឹមត្រូវតាមផ្លូវច្បាប់ ហើយជនជាប់ចោទមានសិទ្ធិទទួលបាននូវការទូទាត់ពេញលេញនូវរយៈពេលដែលខ្លួនជាប់ឃុំ សម្រាប់ជាសំណងចំពោះការរំលោភសិទ្ធិរបស់ជនជាប់ចោទក្នុងក្របខណ្ឌនៃច្បាប់ជាតិនិងអន្តរជាតិ។ អង្គជំនុំជម្រះសាលាដំបូងបានយល់ឃើញផងដែរថាការរំលោភសិទ្ធិរបស់ជនជាប់ចោទដោយតុលាការយោធា មិនអាចបញ្ចូលជាមួយនឹង អ.វ.ត.ក បានទេ ហើយនីតិវិធីរបស់អ.វ.ត.ក គឺមិនមែនជានីតិវិធីដែលបន្តមកពីតុលាការយោធានោះទេ។

អង្គជំនុំជម្រះយល់ឃើញថាការឃុំខ្លួនបណ្តោះអាសន្នគឺជាមធ្យោបាយចាំបាច់សម្រាប់ធានាវត្តមានរបស់ជនជាប់

ចោទក្នុងដំណើរការជំនុំជម្រះក្តី និងដើម្បីការពារសុវត្ថិភាពផ្ទាល់ខ្លួនរបស់ជនជាប់ចោទ ក៏ដូចជាថែរក្សាសណ្តាប់ធ្នាប់សាធារណៈ។ ដោយឈរលើហេតុផលទាំងនេះ អង្គជំនុំជម្រះសាលាដំបូងបញ្ជាថាជនជាប់ចោទត្រូវស្ថិតនៅក្នុងការឃុំខ្លួនបណ្តោះអាសន្នក្នុងរយៈពេលនៃការជំនុំជម្រះក្តីនេះ។

ក្នុងករណីប្រសិនបើរកឃើញថាមានពិរុទ្ធភាព ជនជាប់ចោទនឹងត្រូវបានទូទាត់អំពីពេលវេលាជាប់ឃុំទាំងនៅក្នុងការឃុំខ្លួនបណ្តោះអាសន្ននៅអ.វ.ត.ក និងនៅតុលាការយោធា។

សេចក្តីសម្រេចរបស់អង្គជំនុំជម្រះសាលាដំបូងនេះ មាននៅលើគេហទំព័ររបស់អ.វ.ត.ក ៖ http://www.eccc.gov.kh/khmer/cabinet/courtDoc/305/E39_5_KH.pdf

**សម្រាប់ព័ត៌មានបន្ថែមសូមទាក់ទង**


លោករាជ សម្បត្តិ
ប្រធានផ្នែកកិច្ចការសាធារណៈ
ទូរស័ព្ទចល័តលេខ +855 (0) 12 488 156
សារអេឡិចត្រូនិច reach.sambath@eccc.gov.kh

លោកឡាស អូលសិន
មន្ត្រីទទួលផ្នែកទំនាក់ទំនងផ្លូវច្បាប់
ទូរស័ព្ទចល័តលេខ +855 (0) 12 488 023
ទូរស័ព្ទលេខ +855 (0) 23 219 814 លេខបន្ត 6169
សារអេឡិចត្រូនិច olsen@un.org

Filename: Trial Chamber postpones decision on releasing Duch 15 June khmer
Directory: C:\DOCUME~1\larsO\LOCALS~1\Temp\notes6030C8
Template: D:\Documents and Settings\VuthaM\Desktop\Templates\Letter Head\ECCC Letterhead (KH) .dot
Title: ECCC Letterhead
Subject:
Author: vutham
Keywords:
Comments:
Creation Date: 6/15/2009 4:04:00 PM
Change Number: 4
Last Saved On: 6/15/2009 4:05:00 PM
Last Saved By: larsO
Total Editing Time: 1 Minute
Last Printed On: 6/15/2009 4:05:00 PM
As of Last Complete Printing
Number of Pages: 2
Number of Words: 382 (approx.)
Number of Characters: 2,184 (approx.)